# ជូនសារពត៌មានដើម្បីធ្វើការផ្សព្វផ្សាយបន្ទាន់ URGENT PRESS RELEASE

ថ្ងៃទី ៧ មេសា ១៩៩៥

ពត៌មានផ្សេងៗ សូមទាក់ទងជាមួយ FURTHER INF. PLS CTC MRS. YOU. AKARA: 27626
លោកស្រី ឃូ អក្ខរា អង្គការលីកាដូ ទូរស័ព្ទលេខ: ២៧៦២៦

## ក្រុមអង្គការសិទ្ធិមនុស្សសរសើរដល់រាជរដ្ឋាភិបាលដល់ការចាប់ខ្លួនមន្ត្រីពីរនាក់ ដែលជាប់ទាក់ទងពីរឿងឃាតកម្មនៅ ខេត្តបាត់ដំបង

Human Right really appreciated the govt. arrested two officials concerned with the crime in Battambang

អង្គការសិទ្ធិមនុស្ស អាដហុក និងលីកាដូ សូមសរសើរដល់រាជរដ្ឋាភិបាលខ្មែរ ចំពោះការចាប់ខ្លួនមន្ត្រីយោធាម្នាក់ និងអនុសេនីយឯកប៉ូលីសម្នាក់ ក្នុងពេលថ្មីៗនេះ ដែលបានចូលដៃក្នុងរឿងឃាតកម្មសំលាប់បុរសពីរនាក់ នៅក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី ៥ ខែកុម្ភៈ ១៩៩៥ កន្លងទៅនេះ ។

កាលពីថ្ងៃទី ៣០ ខែមិនា ១៩៩៥ ប៉ូលីសខេត្តបាត់ដំបង បានចាប់ខ្លួនមេបញ្ជាការអនុសេនាតូច គូ វី អាយុ ២៧ ឆ្នាំ នៃកងវិរសេនាតូចលេខ២ ប្រចាំឃុំ មោងឫស្សី ។ នៅថ្ងៃទី ១ ខែមេសា ១៩៩៥ លោកអនុសេនីយឯក ម៉ម រិន អាយុ ៤១ ឆ្នាំ ដែលជាប៉ូលីសស្រុកមោងឫស្សី ក៏ត្រូវបានគេចាប់ខ្លួនដែរ ។ ពួកគេបានរាយការណ៍មកថា អ្នកទាំងពីរនាក់នោះ ត្រូវបានគេចោទពីបទចូលដៃសំលាប់ឈ្មោះ នេត ថុង អាយុ ២៨ ឆ្នាំ និងឈ្មោះ ម៉ូវ រ៉ុង អាយុ ២៨ ឆ្នាំកាលពីថ្ងៃទី ៥ កុម្ភៈ ១៩៩៥ ។ គេមានជំនឿថា ជនទាំងពីរនាក់ដែលត្រូវបានគេចាប់ខ្លួននោះគឺជាមេដឹកនាំក្នុងចំណោមមេដឹកនាំនានា ដែលបានដឹកនាំក្រុមទាហាន ប៉ូលីស សេនាជនទៅចាប់ខ្លួន នេត ថុង និង ម៉ូវ រ៉ុង យកទៅសំលាប់ ។

អង្គការអាដហុក និងលីកាដូ សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមធ្វើការចាប់ និងនាំខ្លួនជនដែលបានប្រព្រឹត្តអំពើសំលាប់មនុស្សទាំងអស់នោះឲ្យតុលាការកាត់ទោសតាមច្បាប់ ។ គេជឿជាក់ថា មានមនុស្សជាច្រើននាក់ទៀតដែលជាប់ទាក់ទង និងទទួលខុសត្រូវនូវអំពើសំលាប់ទាំងនេះ នៅពុំទាន់បានចាប់ខ្លួននៅឡើយ ។ មេកងជីវពលឃុំរបស់មង្គលឈ្មោះ ឆន ក្អាត់ ក៏ត្រូវបានគេរាយការណ៍ថា បានបញ្ជាឲ្យសំលាប់មនុស្សពីរនាក់នោះដែរ ។ តាមពាក្យចចាមរាមថា « កំពុងតែគេចខ្លួន » ។

សព្វថ្ងៃនេះអង្គការអាដហុក និងលីកាដូក៏នៅតែខ្វាយខ្វល់ដល់សុវត្ថិភាពរបស់សមាជិកជនរងគ្រោះដដែល ។ ចាប់តាំងពីមានអំពើឃាតកម្មនោះមក សមាជិកគ្រួសារជនរងគ្រោះតែងតែទទួលការគំរាមគំហែងពីជនដែលគេជឿជាក់ថា ជាអ្នកទទួលខុសត្រូវទាំងនោះ ។